ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខៈ ១៨០ វ.ក

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែកក្កដា ឆ្នាំ ២០១១

# ប្រកាស
## ស្តីពី
## ការគ្រប់គ្រងអាជីវកម្ម សេវាកម្មសម្អាងការ

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល
- បានឃើញ អនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពី រៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- យោងតាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលដៅ គ្រប់គ្រងនិងណែនាំលើអាជីវកម្ម សេវាកម្មសម្អាងការ ក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណង ដើម្បីការពារ និង ថែរក្សានូវទំនៀមទម្លាប់ប្រពៃណី និង អត្តសញ្ញាណជាតិឲ្យបានគង់វង្ស។

**ប្រការ ២.-**

ម្ចាស់អាជីវកម្ម សេវាកម្មសម្អាងការ ត្រូវគោរពទៅតាមរបៀបរបបដែលទាក់ទងទៅនឹងការរៀបចំពិធីមង្គលការជាប្រពៃណីរបស់ជាតិ។

ការប្រើប្រាស់សម្លៀកបំពាក់អាពាហ៍ពិពាហ៍តាមប្រពៃណី ត្រូវគោរពតាមខ្នាតនិងពណ៌សម្បុររបស់ជាតិនិងត្រូវអនុវត្តទៅតាមពេលវេលានៃការរៀបចំពិធីនីមួយៗ។

គ្រឿងអលង្ការជាប្រពៃណីដែលប្រើប្រាស់ក្នុងការតាក់តែងកាយ ត្រូវគោរពទៅតាមបែបបទនិងទម្រង់របស់ជាតិ។

រាល់ដំណើរការក្នុងពិធីមង្គលការតាមប្រពៃណីជាតិ ម្ចាស់សម្អាងការ ត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

**ប្រការ ៣.-**

ម្ចាស់សម្អាងការ ត្រូវមានកម្មវិធីនិងឧបករណ៍សម្ភារៈចាំបាច់ដែលជាតម្រូវការក្នុងការរៀបចំពិធីមង្គលការ។ ករណីគ្មាន ត្រូវពិភាក្សាជាមួយម្ចាស់ដើមពិធីជាមុនដើម្បីរកវិធីដោះស្រាយ។

**ប្រការ ៤.-**

ការផ្លាស់ប្តូរសម្លៀកបំពាក់ កូនកម្លោះ ក្រមុំ ក្នុងពិធីជប់លៀងមង្គលការ ញឹកញាប់ ដែលនាំឲ្យបាត់បង់ទំនៀមទម្លាប់និងសុជីវធម៌ជាតិ ត្រូវហាមឃាត់។

**ប្រការ ៥.-**

រាល់ការច្នៃប្រឌិតណាមួយ ដែលនាំឲ្យប៉ះពាល់ដល់ការបាត់បង់នូវលក្ខណៈដើមនៃប្រពៃណីជាតិ ត្រូវហាមឃាត់។

**ប្រការ ៦.-**

ការបើកទីតាំងអាជីវកម្ម សេវាកម្មសម្អាងការ ត្រូវសុំការអនុញ្ញាតពីមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត ឬ តាមការិយាល័យច្រកចេញចូលតែមួយនៃ ក្រុង ខណ្ឌ ស្រុកគោលដៅដែលបានទទួលការធ្វើប្រតិភូកម្មមុខងារនិងភារកិច្ចពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

រាល់ការអនុញ្ញាតបើកទីតាំងអាជីវកម្ម សេវាកម្មសម្អាងការ ត្រូវមានកម្រៃសេវាកម្ម ដែលកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ តាមតារាងកម្រៃសេវាកម្មរបស់ការិយាល័យច្រកចេញចូលតែមួយនៃ ក្រុង ខណ្ឌ ស្រុកគោលដៅដែលបានទទួលការធ្វើប្រតិភូកម្មមុខងារនិងភារកិច្ចពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ ប្រធាននាយកដ្ឋានសិល្បទស្សនីយភាព ប្រធាននាយកដ្ឋានអភិវឌ្ឍវប្បធម៌ គ្រប់ប្រធានអង្គភាពពាក់ព័ន្ធនិងប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ហ៊ឹម ឆែម

<u>កន្លែងទទួល:</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ